ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីលទ្ធផលមហាសន្និបាតភាគហ៊ុនិកលើកទី៩
# របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ) សូមជម្រាបជូនវិនិយោគិន និងសាធារណជន មេត្តាជ្រាបថា ៖ នាថ្ងៃសុក្រ ១០កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២១ ចាប់ពីម៉ោង ៨:០០ព្រឹក មហាសន្និបាតភាគហ៊ុនិកលើកទី៩ របស់ រ.ទ.ស.ភ តាមប្រព័ន្ធអនឡាញ ZOOM បានដំណើរការទៅតាមកម្មវិធីដែលបានគ្រោងទុក។ មហាសន្និបាតនាពេលនេះ ស្ថិតក្រោម អធិបតីភាព **ឯកឧត្តម អ៊ឹ សុជា** ប្រធានក្រុមប្រឹក្សាភិបាលនៃ រ.ទ.ស.ភ ដោយមានការចូលរួមពីភាគហ៊ុនិកសរុប១១៨រូប គិតជាភាគហ៊ុន មានចំនួន ៧៥.២៦៨.៨៧៧ ស្មើនឹង ៨៦,៥៤% នៃចំនួនភាគហ៊ុនធម្មតាសរុប ក្នុងនោះមាន **ឯកឧត្តម ជូ វណ្ណៈ** អគ្គនាយកនៃនិយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ ជាអាណត្តិគាហកៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មហាសន្និបាតនេះបានប្រព្រឹត្តទៅតាមរបៀបវារៈដូចបានកំណត់ទុក ដែលមានខ្លឹមសារ និងទទួលបានលទ្ធផលដូចខាងក្រោម ៖

**១) របាយការណ៍លទ្ធផលអាជីវកម្មឆ្នាំ២០២០**

| | |
|---|---|
| - ផលិតទឹកស្អាតបាន | ២២៤.៧៧៣.៩៧១ម៣ |
| - បង្កើនអតិថិជនថ្មីបានចំនួន | ១៧.៧១២ បណ្តាញ |
| - ចំណូលសរុបមានចំនួន | ៣២៤.៣៦៧.៨៥៦.០០០រៀល |
| - ចំណេញក្រោយបង់ពន្ធមានចំនួន | ៨៨.៣៥១.៨៤៥.០០០រៀល |
| - ចំណេញជាមូលដ្ឋានក្នុងមួយភាគហ៊ុនគឺ | ១.០១៥,៨៥រៀល។ |

**២) ទិសដៅអាជីវកម្មឆ្នាំ២០២១**

| | |
|---|---|
| - ផលិតទឹកស្អាត | ២២៧.៩៦០.៣៥៨ ម៣ |
| - បង្កើនអតិថិជនថ្មីចំនួន | ២៧.០០៦បណ្តាញ |
| - ចំណូលសរុប | ៣៤៧.៤៤១.៦៦៥.០០០ រៀល |
| - ចំណាយសរុប | ២១៧.៧៦៣.៥៣៥.០០០ រៀល |
| - ចំណេញក្រោយបង់ពន្ធ | ១០៣.៧៤២.៥០៤.០០០រៀល |

**៣) ការបោះឆ្នោតទៅលើកម្មវត្ថុចំនួន២ គឺ៖**

**ក) ការអនុម័តលើការបែងចែកភាគលាភជូនភាគហ៊ុនិក សម្រាប់ឆ្នាំ២០២០**

ការបោះឆ្នោតនេះ មានការចូលរួមពីភាគហ៊ុនិកចំនួន១១៤រូប លើភាគហ៊ុនិកវត្តមានសរុប១១៨រូប គិតជាភាគហ៊ុនមានចំនួន ៧៥.២៦២.៦៩២ភាគហ៊ុន ស្មើនឹង៩៩,៩៩%។



អគារ៤៥ ផ្លូវ ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទៈ(៨៥៥) ២៣ ៦៣៥ ៨០ ៨០ Email: admin@ppwsa.com.kh

មហាសន្និបាតបានឯកភាពបែងចែកភាគលាភឆ្នាំ២០២០ ជាសាច់ប្រាក់ចំនួន ២២.៧៨៦.៩៦៨.៤៤៤រៀល ជូនដល់ភាគហ៊ុនិកដែលមានឈ្មោះក្នុងបញ្ជីភាគហ៊ុនិក នាកាលបរិច្ឆេទកំណត់ទុកថ្ងៃទី២១ ខែមេសា ឆ្នាំ២០២១ ដោយមានសំឡេងបោះឆ្នោតគាំទ្រ ចំនួន ៧៥.២៦២.៦៩២សំឡេង ស្មើនឹង ៩៩,៩៩% នៃភាគហ៊ុនវត្តមាន និងពុំមានសំឡេងមិនគាំទ្រ និងអនុប្បវាទនោះទេ។ ទឹកប្រាក់នេះនឹងត្រូវបែកជូនភាគហ៊ុនិក ចាប់ពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១ ដល់ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២១ ក្នុងទឹកប្រាក់ ២៦២រៀល/ភាគហ៊ុន។

**ខ) ការអនុម័តលើលាភការរបស់ក្រុមប្រឹក្សាភិបាល**

ការបោះឆ្នោតនេះ មានការចូលរួមពីភាគហ៊ុនិកចំនួន១១៤រូប លើភាគហ៊ុនិកវត្តមានសរុប១១៨រូប គិតជាភាគហ៊ុនមានចំនួន ៧៥.២៦២.៦៩២ភាគហ៊ុន ស្មើនឹង៩៩,៩៩%។

មហាសន្និបាតបានឯកភាពទៅលើលាភការរបស់សមាជិកក្រុមប្រឹក្សាភិបាលចំនួន៧រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋអម រ.ទ.ស.ភ ចំនួន១រូប សម្រាប់ឆ្នាំ២០២១ ដែលមានទឹកប្រាក់សរុប ចំនួន ១.០០៧.២៥៤.០០០រៀល ដោយមានសំឡេងបោះឆ្នោតគាំទ្រចំនួន ៧៥.២៤៥.១៨៨ សំឡេង ស្មើនឹង ៩៩,៩៧% នៃភាគហ៊ុនវត្តមាន លើសំឡេងមិនគាំទ្រចំនួន ១១.៣០០សំឡេង ស្មើនឹង ០,០២% នៃភាគហ៊ុនវត្តមាន និងសំឡេងអនុប្បវាទចំនួន ៦.២០៤សំឡេង ស្មើនឹង ០,០១% នៃភាគហ៊ុនវត្តមាន។

អង្គមហាសន្និបាតនេះបានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងក្នុងការបំពេញភារកិច្ចយ៉ាងសកម្មរបស់បុគ្គលិក និយោជិត កម្មករ នៃ រ.ទ.ស.ភ គ្រប់លំដាប់ថ្នាក់ គ្រប់ផ្នែកពាក់ព័ន្ធ ដែលបានចូលរួមបង្កើតស្នាដៃ និងសមិទ្ធផលថ្មីៗធំធេងជាច្រើន ក្នុងការទ្រទ្រង់និងជំរុញសកម្មភាពការងាររបស់ រ.ទ.ស.ភ ឆ្លើយតបទៅនឹងសំណូមពរនៃការផលិតនិងផ្គត់ផ្គង់ទឹកស្អាតជូនដល់ប្រជាពលរដ្ឋ និងតម្រូវការផ្នែកអាជីវកម្ម សេវាកម្ម រួមទាំងជីវភាពសង្គមនានាក្នុងរាជធានីភ្នំពេញ។ អង្គមហាសន្និបាតក៏បានគាំទ្រគម្រោងអាទិភាពក្នុងការពង្រីកសមត្ថភាពផ្គត់ផ្គង់ទឹកស្អាតរបស់ រ.ទ.ស.ភ ដែលបង្ហាញជូនអង្គមហាសន្និបាត និងបានគូសបញ្ជាក់អំពីទិសដៅជាយុទ្ធសាស្ត្រ ដែលត្រូវសម្រេចឱ្យបាននូវគោលនយោបាយផ្គត់ផ្គង់ទឹកស្អាតទីប្រជុំជនឱ្យបាន១០០% នៅឆ្នាំ២០២៥ និងគោលដៅផ្គត់ផ្គង់ទឹកស្អាតនៅរាជធានីភ្នំពេញឆ្នាំ២០៣០។

អង្គមហាសន្និបាតបានបញ្ចប់នៅវេលាម៉ោង១២:២៥រសៀល នាថ្ងៃខែនិងឆ្នាំដដែល ដោយស្ថិតក្រោមបរិយាកាសស្និទ្ធស្នាល រីករាយ និងទទួលខុសត្រូវ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមវិនិយោគិន និងសាធារណជនទទួលជ្រាបជាព័ត៌មាន។

ថ្ងៃសុក្រ ១០កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០២១

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**



អគារ៤៥ ផ្លូវ ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ:(៨៥៥) ២៣ ៦៣៥ ៨០ ៨០ Email: admin@ppwsa.com.kh